# ការជំរុញឲ្យការដាំស្រូវតាមកិច្ចសន្យាមានដំណើរការល្អ សម្រាប់កសិករតូចតាច និងកសិអាជីវកម្ម[១]

## សេចក្តីផ្តើម

ក្នុងសង្គមកម្ពុជា ប្រជាជន ៨០% យករបរកសិកម្មធ្វើជាប្រភពចំណូលចម្បង និងជាមធ្យោបាយចិញ្ចឹមជីវិតរបស់ខ្លួន ក្នុងនេះប្រហែល ២លានគ្រួសារមានផ្ទៃដីដាំដុះជាមធ្យម ១ហិកតា ឬតិចជាង (Mund 2011)។ នៅឆ្នាំ២០១១ កម្ពុជាផលិតស្រូវបាន ៨,៧៨លានតោន ដែលផ្តល់ជាអតិរេកស្រូវសម្រាប់ការនាំចេញ ៣,២១លានតោន (FAO/WFP 2012: 2)។ ប៉ុន្តែការរីកលូតលាស់វិស័យស្រូវអង្ករនេះ មិនបានផ្តល់អត្ថប្រយោជន៍ជាដុំកំភួនដល់កសិករតូចតាចឡើយ ហើយការមានសមត្ថភាពទាបរបស់កសិករ ក្នុងការកែច្នៃផលស្រូវ នៅតែរារាំងដល់ការកែលំអផលិតភាព និងការពង្រីកការនាំចេញ។ ដើម្បីកាត់បន្ថយឧបសគ្គចំពោះវិស័យស្រូវអង្ករ ក្រុមហ៊ុនអង្គរកសិកម្មរុងរឿង (AKR) ដែលជាក្រុមហ៊ុនកម្ពុជាបង្កើតឡើងក្នុងឆ្នាំ ១៩៩៩ ក៏បានបង្កើតគោលនយោបាយ ស្តីពីការដាំស្រូវតាមកិច្ចសន្យាឡើង (Cai *et al.* 2008)។ សព្វថ្ងៃនេះ នៅកម្ពុជាមានព័ត៌មានតិចតួចណាស់ អំពីគម្រោងការដាំស្រូវតាមកិច្ចសន្យា ជាពិសេសទាក់ទងនឹងការឲ្យកសិករតូចតាចចូលរួម ការកាត់បន្ថយភាពក្រីក្រ របៀបរៀបចំកិច្ចសន្យា អត្ថប្រយោជន៍ និងបញ្ហាប្រឈមផ្សេងៗ។

អត្ថបទនេះបង្ហាញពី លទ្ធផលនៃការសិក្សាធំទូលាយមួយដែលពិនិត្យអំពីទិដ្ឋភាពបីនៃការដាំស្រូវតាមកិច្ចសន្យា និងកិច្ចព្រមព្រៀងរវាងកសិករចុះកិច្ចសន្យានឹងAKR។ទិដ្ឋភាពទាំងបីនោះគឺការឲ្យម្ចាស់ដីកសិកម្មតូចៗចូលរួម និងរបៀបរៀបចំកិច្ចសន្យា អត្ថប្រយោជន៍នៃការដាំស្រូវតាមកិច្ចសន្យាចំពោះកសិករ និងការលំបាកដែលកសិករ និងសហគ្រាសកសិអាជីវកម្មជួបប្រទះ។ សម្រាប់ករណីសិក្សា អ្នកស្រាវជ្រាវបានជ្រើសយក AKR ព្រោះជាក្រុមហ៊ុនផលិតស្រូវតាមកិច្ចសន្យាធំបំផុតនៅកម្ពុជា។ ការវិភាគផ្អែកលើទិន្នន័យបានពី ការធ្វើសម្ភាសន៍បែបគុណភាពនៅក្នុងខេត្តកំពង់ស្ពឺ កាលពីខែឧសភា ២០១២ និង មិថុនា ២០១៣។ អ្នកឆ្លើយសម្ភាសន៍រួមមាន កសិករ ១០នាក់ មេភូមិ ៤នាក់ បុគ្គលិកឃុំ ១នាក់ បុគ្គលិក AKR ១នាក់ និង បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលក្នុងតំបន់នោះចំនួន ៣នាក់។ លទ្ធផលពីការសិក្សា នឹងរួមចំណែកជួយដោះស្រាយបញ្ហាផ្សេងៗផ្នែកគោលនយោបាយ ដែលសំខាន់ជាខ្លាំងសម្រាប់ជោគជ័យនៃការដាំស្រូវតាមកិច្ចសន្យា និងជួយដល់ការរៀបចំវិធីសាស្ត្រអភិវឌ្ឍន៍មួយដែលជម្រុញឲ្យការដាំស្រូវតាមកិច្ចសន្យា អាចដំណើរការបានសម្រាប់កសិករតូចតាច។

## ការឲ្យកសិករតូចតាចចូលរួម និងរបៀបរៀបចំកិច្ចសន្យា

នៅពេលចាប់ផ្តើមប្រតិបត្តិការដាំស្រូវតាមកិច្ចសន្យា ក្រុមហ៊ុន AKR បានពិចារណាលើកត្តាជាច្រើនក្នុងការសម្រេចជ្រើសរើសកន្លែងអនុវត្តគម្រោងការចុះកិច្ចសន្យានេះ។ កត្តាដ៏សំខាន់បំផុតគឺលក្ខខណ្ឌផ្នែកក្សេត្រសាស្ត្រ។ ស្រូវផ្កាម្លិះ ត្រូវបានជ្រើសរើសព្រោះវាជាពូជស្រូវដែលសមស្របសម្រាប់តំបន់ទំនាប ដែលពឹងផ្អែកលើទឹកភ្លៀង និងមិនសូវជួបគ្រោះទឹកជំនន់។ ដោយសារស្ថានភាពក្សេត្រសាស្ត្រមិនសមស្រប មាន ឃុំ ភូមិមួយចំនួន និងកសិករខ្លះ ដែលស្ថិតក្នុងខេត្តជាមួយគ្នាដែរ ពុំមានការអនុញ្ញាតឲ្យចូលរួមក្នុងគម្រោងការដាំស្រូវតាមកិច្ចសន្យាទេ។ លក្ខណៈវិនិច្ឆ័យមួយទៀត គឺកម្រិតប្រមូលផ្តុំផលិតកម្មនៅក្នុងតំបន់។ តម្រូវការពូជស្រូវសុទ្ធកម្រិតខ្ពស់ នាំឲ្យមានការដកចេញនូវភូមិខ្លះពីគម្រោង ដោយហេតុថាកសិករចង់ចុះកិច្ចសន្យានៅក្នុងភូមិទាំងនោះ មានដីស្រែនៅរាយប៉ាយដាច់ឆ្ងាយពីគ្នា។ ពីដំបូង ទំហំស្រែមិនមែនជា លក្ខខណ្ឌសម្រាប់ការជ្រើសរើសកសិករនោះទេ ប៉ុន្តែនៅឆ្នាំ២០០០ មានតែ ៥% នៃកសិករចុះកិច្ចសន្យាជាមួយ AKR ប៉ុណ្ណោះ ដែលមានដីស្រែតូចជាង ១ហិកតា។ ក្រោយមក ក្រុមហ៊ុន AKR ក៏គិតឃើញថា ការធ្វើការជាមួយកសិករមានដីស្រែតូចៗវាលំបាកពេក ហើយក៏បានបង្កើតវិធានកំណត់ដីស្រែ ១ហិកតានេះឡើង។ ជារឿយៗស្ថានភាពជីវភាពយ៉ាប់យ៉ឺនបានបង្ខំឲ្យកសិករមានដីស្រែតូចៗ អនុវត្តបំពានលើកិច្ចសន្យា ហើយរារាំងក្រុមហ៊ុន ក្នុងការចាត់វិធានការតាមផ្លូវច្បាប់ចំពោះពួកគាត់។ គោលនយោបាយបច្ចុប្បន្ននៃការទិញស្រូវជាសមូហភាព ជួយឲ្យកសិករមានដីស្រែតូចៗ អាចលក់ស្រូវទៅឲ្យក្រុមហ៊ុន AKR បាន ប៉ុន្តែក្រុមហ៊ុនមិនបានកត់ត្រាពីចំនួនកសិករប្រភេទនេះនៅក្នុងគម្រោងការរបស់ខ្លួនទេ។ ដូច្នេះ គម្រោងការធ្វើស្រែតាមកិច្ចសន្យា មិនបានរើសអើងចំពោះកសិករក្រីក្រ ឬក្រីក្រខ្លាំងនោះឡើយ។

ក្រុមហ៊ុនAKRបានបង្កើតជាសមាគមឃុំ ដើម្បីកសាងទំនុកចិត្តជាមួយកសិករ និងធានានូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពលើការផ្គត់ផ្គង់។ សមាគមឃុំមានតួនាទីជាច្រើន ដូចជា ជួយ AKR ជ្រើសរើសកសិករចុះកិច្ចសន្យា, វាយតម្លៃការប្តេជ្ញាចិត្ត និងភាពសមស្របផ្នែកក្សេត្រសាស្ត្ររបស់កសិករ ពិនិត្យតាមដានកសិករជាប់កិច្ចសន្យានានា និងផ្តល់ដំណឹងពីដំណើរការផលិតកម្ម និងបញ្ហាប្រឈមផ្សេងៗដល់ AKR ។

កិច្ចសន្យារវាង AKR និងកសិករ មិនមានការចូលរួមពីកសិករទេនៅពេលតាក់តែងរៀបចំឡើង។ ក្រុមហ៊ុនជាអ្នកតាក់តែងកិច្ច

[១] រៀបរៀងដោយ នូ កែវសុទ្ធា ជាអ្នកសម្របសម្រួលកម្មវិធី និងបណ្ឌិត ហេង ម៉ូលីយ៉ាណែត ជាអ្នកស្រាវជ្រាវ នៃកម្មវិធីអភិវឌ្ឍន៍សង្គម។ អត្ថបទនេះ សង្ខេបពីលទ្ធផលសិក្សាដែលបានអនុវត្តឡើងជាផ្នែកមួយនៃ គម្រោង ACIAR (ASEM/2009/023) ស្តីពី "ការបង្កើតគោលនយោបាយកសិកម្មសម្រាប់ប្រព័ន្ធកសិកម្មផ្អែកលើដំណាំស្រូវ នៅប្រទេសឡាវ និងកម្ពុជា" ដែលគ្រោងបញ្ចប់នៅខែឧសភា ២០១៤។

សន្យា ហើយកសិករក៏ចុះហត្ថលេខាលើនោះ។ កិច្ចសន្យាមានចែងពីលក្ខខណ្ឌដ៏ចាំបាច់មួយចំនួន ប៉ុន្តែនៅខ្វះចំណុចសំខាន់ៗជាច្រើន។ ការចុះកិច្ចសន្យាផ្គត់ផ្គង់ស្រូវឲ្យ AKR ជួយឲ្យកសិករទទួលបាន គ្រាប់ពូជមានគុណភាពខ្ពស់ (ពីដំបូងមានតែស្រូវផ្កាម្លិះប៉ុណ្ណោះ ប៉ុន្តែថ្មីៗនេះទៀត មានស្រូវ ផ្ការំដួល និងអង្គង់សីយ ផងដែរ) សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ទីផ្សារមានការធានាល្អ និងថ្លៃស្រូវមានលក្ខណៈប្រកួតប្រជែង។ កិច្ចសន្យាគ្មានបញ្ជាក់ពីថ្លៃទិញស្រូវទេ ប៉ុន្តែមានចែងថា កសិករនឹងទទួលបាន ៦០រៀល/គីឡូក្រាម លើសពីថ្លៃទីផ្សារនៅពេលលក់ស្រូវ។ ក្នុងផ្ទៃដីចុះកិច្ចសន្យាមួយហិកតាៗ AKR រំពឹងថាទទួលបានការផ្គត់ផ្គង់ស្រូវពី ១,៥ ទៅ ២,៥តោន ប៉ុន្តែវិធាននេះអាចលើកលែងបានក្នុងករណីផលស្រូវរងការខូចខាត។ កិច្ចសន្យាក៏មានបញ្ជាក់ដែរពីបរិមាណគ្រាប់ពូជដែលកសិករអាចខ្ចីបាន ប៉ុន្តែគ្មានបញ្ជាក់ពីរយៈពេលនៃការខ្ចីនោះទេ។ កិច្ចសន្យាមានចែងពី កាតព្វកិច្ចរបស់ AKR ក្នុងការចេញថ្លៃដឹកជញ្ជូនស្រូវទៅកាន់ក្រុមហ៊ុន និងបង់ថ្លៃសេវាទៅឲ្យសមាជិកសមាគមឃុំ ពីលក្ខខណ្ឌដែលក្រុមហ៊ុនទទួលទិញស្រូវពីកសិករ ពីការពិន័យលើកសិករដែលអនុវត្តបំពានលើកិច្ចសន្យា ប៉ុន្តែគ្មានចែងពីការពិន័យលើក្រុមហ៊ុនទេ។ កិច្ចសន្យាក៏គ្មានចែងពី ពេលវេលាដែលកសិករត្រូវបង្វិលសងគ្រាប់ពូជមកវិញ រយៈពេលនៃកិច្ចសន្យា និងបែបបទដែលភាគីណាមួយអាចបញ្ចប់កិច្ចសន្យាបាន។

## អត្ថប្រយោជន៍នៃការដាំស្រូវតាមកិច្ចសន្យា

លទ្ធភាពចូលទៅកាន់ទីផ្សារ ដែលមានលក្ខណៈប្រកួតប្រជែង គឺជាហេតុផលចម្បង និងសំខាន់បំផុតសម្រាប់កសិករចូលរួមក្នុងគម្រោងការដាំស្រូវតាមកិច្ចសន្យា។ ថ្លៃដែល AKR ទទួលទិញស្រូវពីកសិករ មានលក្ខណៈប្រកួតប្រជែងពីរបែប៖ ១) ថ្លៃប្រមូលទិញវាខ្ពស់ជាងច្រើន បើធៀបនឹងថ្លៃដែលកសិករអាចទទួលបានពីប្រភេទស្រូវធម្មតា ដូចជា ចុងបន្លា និង ក្រចកចាប និង ២) ថ្លៃប្រមូលទិញរបស់ AKR គឺខ្ពស់ជាងថ្លៃប្រមូលទិញរបស់ឈ្មួញក្រៅផ្លូវការ។ ប៉ុន្តែថ្លៃខ្ពស់របស់ AKR នេះ ក៏មានលក្ខខណ្ឌបង្កជាបញ្ហាប្រឈមផ្នែកផលិតកម្មច្រើនដែរ (ឧទាហរណ៍ ការតម្រូវតឹងរ៉ឹងនូវប្រភេទពូជស្រូវ និងកម្រិតសំណើម) ដែលរារាំងកសិករមួយចំនួន ក្នុងការចូលរួមចុះកិច្ចសន្យា។ វត្តមានរបស់ AKR និង មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CEDAC) បង្កើតជាទីផ្សារមានលក្ខណៈប្រកួតប្រជែងមួយ ដែលរារាំងឈ្មួញក្រៅផ្លូវការក្នុងការបន្ទាបថ្លៃស្រូវមិនសមហេតុផល។ ដោយបានយល់ដឹងពីកម្លាំងឌីណាមិកទាំងនេះ កសិករខ្លះបានពិចារណារក្សាសមាជិកភាពរបស់ខ្លួននៅក្នុង AKR ឬ CEDAC ដើម្បីរក្សាថ្លៃទីផ្សារនៃស្រូវផ្កាម្លិះឲ្យនៅខ្ពស់រហូត ទោះបីមានបញ្ហាប្រឈមផ្នែកផលិតកម្មក្តី។

អត្ថប្រយោជន៍សំខាន់បំផុតទី២ គឺលទ្ធភាពទទួលបានគ្រាប់ពូជគុណភាពល្អ។ នៅដំណាក់កាលដំបូងនៃការដាំស្រូវតាមកិច្ចសន្យា ដែលសម្រាប់បម្រើទីផ្សារក្នុងស្រុក និងការហូបចុកតាមផ្ទះនោះ កសិករមិនសូវយកចិត្តទុកដាក់ថា ផលស្រូវមានពូជសុទ្ធល្អប៉ុណ្ណានោះទេ។ នៅពេលកើតមានទីផ្សារនាំចេញ ការទទួលបានគ្រាប់ពូជគុណភាពល្អ បានក្លាយជាហេតុផលចម្បងទាក់ទាញកសិករឲ្យចូលរួមក្នុង គម្រោងការដាំស្រូវតាមកិច្ចសន្យារបស់ AKR ព្រោះ AKR មានផ្គត់ផ្គង់គ្រាប់ពូជផ្ដល់ទិន្នផលខ្ពស់ និងមានភាពសុទ្ធល្អ ដែលជាលក្ខខណ្ឌមួយសម្រាប់ទីផ្សារនាំចេញអង្ករគុណភាពខ្ពស់។ CEDAC ក៏បានទិញស្រូវផ្កាម្លិះពីកសិករដែរ ប៉ុន្តែពុំមានគោលនយោបាយផ្ដល់គ្រាប់ពូជគុណភាពល្អ ឲ្យកសិករខ្ចីឡើយ។

លទ្ធភាពទទួលបានសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ជាអត្ថប្រយោជន៍ទី៣ នៃការដាំស្រូវតាមកិច្ចសន្យាជាមួយ AKR។ សេវានេះមិនមែនមានតែ AKR ជាអ្នកផ្ដល់ឲ្យនោះទេ ព្រោះអង្គការមិនមែនរដ្ឋាភិបាល នៅតាមមូលដ្ឋានខ្លះ ក៏មានផ្ដល់ឲ្យកសិករដែរ។ អត្ថប្រយោជន៍បន្ទាប់បន្សំទទួលបានពី AKR មានជាអាទិ៍ ឥណទានមានការប្រាក់ទាប ការបង់ថ្លៃសេវាទៅឲ្យសមាគមឃុំ ការចេញថ្លៃដឹកស្រូវទៅក្រុមហ៊ុន និងប្រព័ន្ធវាស់វែង និងថ្លឹងត្រឹមត្រូវល្អ និងយុត្តិធម៌។

អត្ថប្រយោជន៍ដូចខាងលើ ជួយធ្វើឲ្យកសិករអាចបង្កើនប្រាក់ចំណូលពីការដាំស្រូវ។ ចំណូល និងប្រាក់ចំណេញរបស់កសិករចុះកិច្ចសន្យា មានកម្រិតខ្ពស់ជាងកសិករមិនចុះកិច្ចសន្យា (មិនធ្លាប់ចូលរួមក្នុងគម្រោង) ប៉ុន្តែនៅទាបជាងកសិករធ្លាប់បានចុះកិច្ចសន្យាកាលពីមុន (បានចូលរួមក្នុងគម្រោង និងឈប់ពីគម្រោងវិញ) (តារាង ១ និង ២)។ ភាពខុសគ្នារវាងចំណូល និងប្រាក់ចំណេញរបស់កសិករចុះកិច្ចសន្យា និងមិនចុះកិច្ចសន្យា អាចពន្យល់បានថា ជាលទ្ធផលនៃចំណេះដឹងផ្នែកផលិតកម្ម និងថ្លៃទិញស្រូវខ្ពស់ជាងដែលផ្ដល់ដោយ AKR។ ដោយឡែក កសិករធ្លាប់ចុះកិច្ចសន្យាកាលពីមុនគាត់មានលទ្ធភាពគ្រប់គ្រងបានច្រើនជាងទៅលើ ការងារផលិតកម្មដែលជាប់ទាក់ទងនឹង ការប្រើពូជសុទ្ធ និងកម្រិតសំណើម ព្រោះគាត់លក់ស្រូវទៅឲ្យឈ្មួញក្រៅផ្លូវការដែលមិនដាក់លក្ខខណ្ឌអ្វីលើការទិញឡើយ។

## បញ្ហាប្រឈមនៃការដាំស្រូវតាមកិច្ចសន្យា

ភាពសុទ្ធនៃគ្រាប់ពូជ និងកម្រិតសំណើមទាប ជាលក្ខណៈវិនិច្ឆ័យសំខាន់បំផុតពីរ ដែលគេប្រើដើម្បីកំណត់ថា ស្រូវមានគុណភាពល្អសមស្រប សម្រាប់នាំចេញទៅទីផ្សារអង្ករគុណភាពខ្ពស់។ អតីតកសិករធ្លាប់ចុះកិច្ចសន្យាជាមួយ AKR មួយចំនួន បានលើកឡើងថា ការមិនអាចបំពេញតាមលក្ខណៈវិនិច្ឆ័យសំខាន់ទាំងពីរចំណុចខាងលើនេះ (ភាពសុទ្ធនៃគ្រាប់ពូជ និងកម្រិតសំណើមទាប) គឺជាមូលហេតុចម្បង ដែលគាត់បញ្ឈប់កិច្ចសន្យាជាមួយ AKR ទោះបីជាក្រុមហ៊ុនឲ្យថ្លៃខ្ពស់ជាងក្តី។ ឈ្មួញក្រៅផ្លូវការឲ្យថ្លៃទាបជាងក៏ពិតមែន ប៉ុន្តែមិនមានដាក់លក្ខខណ្ឌអ្វីឡើយ។ AKR យល់ឃើញថា បរាជ័យក្នុងការផលិតស្រូវ មានពូជសុទ្ធកម្រិតខ្ពស់របស់កសិករ គឺបណ្ដាលមកពីកង្វះការប្ដេជ្ញាចិត្ត។ នេះជាមូលហេតុដែលក្រុមហ៊ុន បានលុបចោលកិច្ចសន្យាជាមួយពួកគេ។ ប៉ុន្តែក្រុមហ៊ុន ក៏ដឹងពីកង្វះខាតរបស់ខ្លួនដែរ ដែលមិនមានម៉ាស៊ីនសម្ងួតស្រូវ សម្រាប់ឲ្យក្រុមហ៊ុនអាចទិញស្រូវសើមពីកសិករតែម្ដង។ កង្វះខាតនេះ ធ្វើឲ្យ AKR មិនអាចបំពេញបានតាមតម្រូវការនាំចេញ ជាពិសេសតម្រូវការពីទីផ្សារអង្ករគុណភាព

ខ្ពស់ ហើយក្រុមហ៊ុនត្រូវបង្ខំចិត្ត ទិញស្រូវស្ងួតជាស្រេចពីឈ្មួញក្រៅផ្លូវការ។

លទ្ធភាពតិចក្នុងការទទួលបានគ្រាប់ពូជគុណភាពខ្ពស់ ជាបញ្ហាប្រឈមមួយទៀតចំពោះកសិករ។ លក្ខខណ្ឌនៃកិច្ចសន្យាតម្រូវឲ្យ AKR ផ្តល់គ្រាប់ពូជឲ្យកសិករខ្ចីដោយមិនគិតការប្រាក់ ប៉ុន្តែកិច្ចសន្យាគ្មានបញ្ជាក់ពីខួបនៃការផ្តល់កម្ចីទេ។ គ្រោះរាំងស្ងួត និងកង្វះការប្តេជ្ញាចិត្តរបស់កសិករចុះកិច្ចសន្យា បានធ្វើឲ្យថយចុះទិន្នផលស្រូវ និងកម្រិតសុទ្ធល្អនៃពូជស្រូវ ដែលជាការខាតបង់យ៉ាងធ្ងន់សម្រាប់ AKR។ ដោយរៀនសូត្រពីបទពិសោធន៍នេះ ក្រុមហ៊ុនផ្តល់កម្ចីគ្រាប់ពូជ ដល់ឃុំមួយចំនួនតូច ដែលក្រុមហ៊ុនយល់ឃើញថា កសិករមានការប្តេជ្ញាចិត្តអនុវត្តតាមការតម្រូវដ៏តឹងរ៉ឹងរបស់ខ្លួន។ អង្គការក្នុងមូលដ្ឋាន ក៏មានផ្តល់គ្រាប់ពូជឲ្យកសិករខ្ចីដែរ ប៉ុន្តែគម្រោងនោះមិនអាចផ្គត់ផ្គង់កសិករបានគ្រប់គ្នាទេ ហើយគ្រាប់ពូជផ្តល់ឲ្យ ក៏ខុសគ្នាពីប្រភេទស្រូវដែល AKR ទទួលទិញផងដែរ។

ការបង់ប្រាក់មិនទៀងទាត់របស់ AKR សម្រាប់ទូទាត់ថ្លៃដឹកស្រូវទៅដល់ក្រុមហ៊ុន និងថ្លៃសេវារបស់សមាគមឃុំ បានបង្កការលំបាកដល់កសិករចុះកិច្ចសន្យា និងសមាជិកសមាគម។ កិច្ចសន្យាចែងថា AKR ត្រូវបង់ថ្លៃចំណាយទាំងនេះ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង ក្រុមហ៊ុនមិនបានបំពេញកាតព្វកិច្ចនេះទៀងទាត់ទេ។ ប្រការនេះបង្កឲ្យមានការខាតបង់ផ្នែកហិរញ្ញវត្ថុដល់កសិករចុះកិច្ចសន្យា។ ក្រុមហ៊ុនក៏បានសន្យាទៀតថា នឹងផ្តល់ប្រាក់ ៣០រៀល ទៅឲ្យមេឃុំ និង ៤០រៀល ទៅឲ្យមេភូមិ សម្រាប់រាល់ការផ្គត់ផ្គង់អង្ករ ១គីឡូក្រាម ដោយសមាជិករបស់ពួកគាត់ ប៉ុន្តែ ក្រុមហ៊ុនអនុវត្តតាមការសន្យានេះតែម្តងម្កាលប៉ុណ្ណោះ។ កិច្ចសន្យាបានកំណត់តាមផ្លូវច្បាប់នូវកាតព្វកិច្ចរបស់គូភាគី ប៉ុន្តែ កសិករមិនមានសិទ្ធិអំណាចតម្រូវឲ្យក្រុមហ៊ុនទទួលខុសត្រូវលើសកម្មភាពរបស់ខ្លួន ឬទាមទារសំណងលើការបំពានកិច្ចសន្យានោះឡើយ។ ខាង AKR វិញ ក៏ត្រូវប្រឈមមុខនឹងការអនុវត្តខុសកិច្ចសន្យា ដែលបង្កឡើងដោយកសិករដែរ។ AKR ក៏

តារាង ១៖ ទិន្នផល ថ្លៃ និងប្រាក់ចំណូល ទទួលបានលើស្រូវវស្សា គិតតាមប្រភេទកសិករ (ឆ្នាំ ២០១២)

| | ឯកតា | អតីតកសិករ ចុះកិច្ចសន្យា | អតីតកសិករ ចុះកិច្ចសន្យា | កសិករមិនចុះ កិច្ចសន្យា |
|---|---|---|---|---|
| ទំហំដី | ហិកតា | 1 | 1 | 1 |
| ទិន្នផល | គីឡូក្រាម/ហិកតា | 2500 | 2000 | 2000 |
| ថ្លៃ | រៀល/គីឡូក្រាម | 1350 | 1450 | 1350 |
| ចំណូលសរុប | រៀល/ហិកតា | 3375000 | 2900000 | 2700000 |
| ចំណូលៈ កសិករចុះកិច្ចសន្យា ធៀបនឹងកសិករមិនចុះកិច្ចសន្យា | រៀល/ហិកតា | | 200000 | 0 |
| | % | | 107 | 100 |
| ចំណូលៈ អតីតកសិករចុះកិច្ចសន្យា ធៀបនឹងកសិករចុះកិច្ចសន្យា | រៀល/ហិកតា | 475000 | 0 | |
| | % | 116 | 100 | |
| ចំណូលៈ អតីតកសិករចុះកិច្ចសន្យា ធៀបនឹងកសិករមិនចុះកិច្ចសន្យា | រៀល/ហិកតា | 675000 | | 0 |
| | % | 125 | | 100 |

ប្រភពៈ ការគណនារបស់អ្នកនិពន្ធផ្អែកលើព័ត៌មានបានពីសម្ភាសន៍

តារាង ២៖ ការប្រៀបធៀបប្រាក់ចំណេញ គិតតាមប្រភេទកសិករ (ឆ្នាំ២០១២)

| | ឯកតា | អតីតកសិករ ចុះកិច្ចសន្យា | កសិករចុះកិច្ចសន្យា | កសិករមិនចុះ កិច្ចសន្យា |
|---|---|---|---|---|
| ចំណូលសរុប | រៀល/ហិកតា | 3375000 | 2900000 | 2700000 |
| ចំណាយសរុប | រៀល/ហិកតា | 1230000 | 986000 | 1000000 |
| ប្រាក់ចំណេញ | រៀល/ហិកតា | 2145000 | 1914000 | 1700000 |
| ប្រាក់ចំណេញៈ កសិករចុះកិច្ចសន្យា ធៀបនឹងកសិករមិនចុះកិច្ចសន្យា | រៀល/ហិកតា | | 214000 | 0 |
| | % | | 113 | 100 |
| ប្រាក់ចំណេញៈ អតីតកសិករចុះកិច្ចសន្យា ធៀបនឹងកសិករចុះកិច្ចសន្យា | រៀល/ហិកតា | 231000 | 0 | |
| | % | 112 | 100 | |
| ប្រាក់ចំណេញៈ អតីតកសិករចុះកិច្ចសន្យា ធៀបនឹងកសិករមិនចុះកិច្ចសន្យា | រៀល/ហិកតា | 445000 | | |
| | % | 126 | | 100 |

ប្រភពៈ ការគណនារបស់អ្នកនិពន្ធផ្អែកលើព័ត៌មានបានពីសម្ភាសន៍

បានលើកឡើងនូវបញ្ហាចម្បងស្តីពី ការលក់ទៅទីផ្សារខាងក្រៅខុសពីកិច្ចសន្យា ពោលគឺ កសិករបានលក់ទៅឲ្យឈ្មួញផ្សេងទៀតនូវស្រូវដែលត្រូវលក់ទៅឲ្យ AKR។ ទោះជាយ៉ាងនេះក្តី ក៏មកទល់សព្វថ្ងៃ មិនទាន់មានសមាជិកចុះកិច្ចសន្យាណាមួយដែលត្រូវជាប់ពិន័យ ដោយសារការអនុវត្តបំពានកិច្ចសន្យានោះទេ។ បញ្ហាមួយទៀតដែល AKR លើកឡើង គឺការប្រើប្រាស់មិនត្រឹមត្រូវនូវប័ណ្ណសមាជិក។ តាមសេចក្តីរាយការណ៍ កសិករខ្លះបានឲ្យសាច់ញាតិ ឬមិត្តភក្តិខ្លួនខ្ចីប័ណ្ណនោះប្រើប្រាស់ ឬ "ជួល" ទៅឲ្យឈ្មួញក្រៅផ្លូវការ ដែលយកប័ណ្ណនោះទៅប្រើ ដើម្បីបានចំណេញពីថ្លៃទិញស្រូវខ្ពស់របស់ AKR។

ការទទួលបានឥណទានមិនគ្រប់គ្រាន់ បានបង្កឧបសគ្គជាច្រើនដល់កសិករចុះកិច្ចសន្យា និង AKR ។ កសិករដែលខ្វះខាតឥណទាន ត្រូវបង្ខំចិត្តលក់ស្រូវទៅឲ្យឈ្មួញក្រៅផ្លូវការ បន្ទាប់ពីការប្រមូលផល ដើម្បីទទួលបានប្រាក់ភ្លាមៗ។ ស្រដៀងគ្នានេះដែរ កសិករក៏ស្ទាក់ស្ទើរក្នុងការផ្គត់ផ្គង់ស្រូវទៅឲ្យ AKR ដោយសារក្រុមហ៊ុនច្រើនតែពន្យាពេល ការទូទាត់ប្រាក់ទៅឲ្យកសិករ ដែលជាហេតុនាំឲ្យពួកគេជួបការលំបាកផ្នែកហិរញ្ញវត្ថុ។ បន្ថែមលើនេះទៀត កសិករចុះកិច្ចសន្យា ដែលមានកាតព្វកិច្ចផ្គត់ផ្គង់ស្រូវទៅឲ្យ AKR ត្រូវបានក្រុមហ៊ុនជំពាក់ ដែលបណ្តាលឲ្យកសិករមួយចំនួនធំ ត្រូវចាកចេញពីគម្រោងការដាំស្រូវតាមកិច្ចសន្យា។ ផ្ទុយទៅវិញ ឈ្មួញក្រៅផ្លូវការតែងសម្រួលដល់ការលក់ដូររបស់កសិករ ដោយមិនដាក់លក្ខខណ្ឌទាក់ទងនឹងកម្រិតសំណើម និងពូជសុទ្ធ និងដោយបង់ប្រាក់ឲ្យភ្លាមៗ។ ចាប់ពីឆ្នាំ២០១០ មក ក្រុមហ៊ុនបានកែលំអរបៀបរបបហិរញ្ញវត្ថុរបស់ខ្លួន ហើយបង់ប្រាក់ទៅឲ្យសមាជិកខ្លួនភ្លាម នៅពេលដឹកស្រូវដល់ក្រុមហ៊ុន ប៉ុន្តែ គេនៅមិនទាន់ច្បាស់លាស់ទេថា AKR អាចបង់ប្រាក់ភ្លាមៗដូច្នេះបានយូរប៉ុណ្ណា។ ឧបសគ្គផ្នែកឥណទាន ក៏រារាំង AKR ក្នុងការធ្វើវិនិយោគលើឧបករណ៍សម្ងួតស្រូវ ដែលអាចជួយក្រុមហ៊ុនឲ្យបន្ធូរលក្ខខណ្ឌតឹងតែង ស្តីពីកម្រិតសំណើម និងទទួលទិញស្រូវសើមពីកសិករបាន។

គ្រោះធម្មជាតិ មានផលប៉ះពាល់អវិជ្ជមានដោយផ្ទាល់ ទៅលើផលិតកម្មស្រូវរបស់កសិករចុះកិច្ចសន្យា និងមានផលប៉ះពាល់ដោយប្រយោលទៅលើ AKR។ ការខូចខាតផលស្រូវដោយសារគ្រោះរាំងស្ងួត បានប៉ះទង្គិចធ្ងន់ធ្ងរណាស់ទៅលើកសិករ ពោលគឺទិន្នផលអាចចុះទាបធ្វើឲ្យពួកគេមិនអាចផលិតស្រូវបានគ្រប់គ្រាន់ដើម្បីបំពេញតាមកិច្ចសន្យា។បុគ្គលិកAKRបានរាយការណ៍ថាការខាតបង់ជារឿយៗដោយសារគ្រោះរាំងស្ងួត បានបង្ខំឲ្យក្រុមហ៊ុនត្រូវបញ្ឈប់កិច្ចសន្យាជាមួយឃុំជាច្រើន ដែលងាយរងគ្រោះដោយបាតុភូតធម្មជាតិនេះ។

## សេចក្តីសន្និដ្ឋាន និងជម្រើសគោលនយោបាយ

សរុបមក របៀបចុះកិច្ចសន្យាធ្វើកសិកម្មរបស់ AKR បានវិវត្តទៅមុខ ដោយផ្តល់លទ្ធភាពកាន់តែច្រើនឡើងទៅឲ្យគ្រួសារក្រីក្រ និងគ្រួសារក្រីក្របំផុតចូលរួម ជាពិសេស តាំងពីការដាក់អនុវត្ត គោលនយោបាយទិញជាសមូហភាព។ ការទទួលបានអត្ថប្រយោជន៍សំខាន់ៗ បានបង្កើនប្រាក់ចំណេញ ដែលកសិករចុះកិច្ចសន្យាទទួលបានពីដំណាំស្រូវ។ ប៉ុន្តែការអនុវត្តកិច្ចសន្យាមិនបានល្អ និងការតម្រូវឲ្យផលិតផលស្រូវមានគុណភាពខ្ពស់ បានបង្កើតបញ្ហាប្រឈមច្រើនស្មុគស្មាញ ដែលត្រូវតែដោះស្រាយ បើសិនចង់ឲ្យការធ្វើកសិកម្មតាមកិច្ចសន្យា ផ្តល់ផលប្រយោជន៍ដល់ទាំងកសិករតូចតាច និងសហគ្រាសកសិពាណិជ្ជកម្ម។ កិច្ចសន្យាធ្វើកសិកម្មផ្តោតចំទិសល្អ អាចជួយបង្កើនអត្ថប្រយោជន៍ដល់ភាគីទាំងពីរ និងចូលរួមចំណែកដល់ការអភិវឌ្ឍវិស័យស្រូវអង្ករ និងកាត់បន្ថយភាពក្រីក្រនៅជនបទ។ ខាងក្រោមនេះ ជាជម្រើសគោលនយោបាយមួយចំនួន ដែលរដ្ឋាភិបាលគួរពិនិត្យពិចារណា៖

១. **បង្កើនចំណាប់អារម្មណ៍របស់កសិករ អំពីបន្ទុកចំណាយ និងអត្ថប្រយោជន៍នៃការធ្វើកសិកម្មតាមកិច្ចសន្យា៖** ការមានជំនាញកាន់តែប្រសើរអំពីការធ្វើអាជីវកម្ម អាចជួយឲ្យកសិករមានការតាំងចិត្តខ្ពស់ បំពេញតាមកិច្ចសន្យាជាមួយ AKR។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) អាចផ្តល់ព័ត៌មាន និង/ឬ ការបណ្តុះបណ្តាលអំពី ការវិភាគចំណាយ និងផលចំណេញ តាមរយៈសេវាផ្សព្វផ្សាយបច្ចេកទេសរបស់ខ្លួន ឬក៏តាមសមាគមក្នុងឃុំនានា ដែល AKR បានបង្កើតឡើង។

២. **លុបបំបាត់ឧបសគ្គបច្ចេកទេស លើការសម្ងួតស្រូវ៖** MAFF អាចរួមសហការជាមួយ វិទ្យាស្ថានអន្តរជាតិស្រាវជ្រាវដំណាំស្រូវ (IRRI) ដើម្បីផ្តល់ការបណ្តុះបណ្តាលពីបច្ចេកទេសសម្ងួត ហើយរដ្ឋាភិបាលអាចលើកទឹកចិត្តវិស័យឯកជន (ឧទាហរណ៍ រោងចក្រកិនស្រូវ) ឲ្យធ្វើវិនិយោគលើបច្ចេកទេសសម្ងួត និង/ឬ ផ្តល់កម្ចី/ឥណទានកសិកម្ម ឲ្យ AKR ធ្វើវិនិយោគលើម៉ាស៊ីនសម្ងួតស្រូវខ្នាតធំ។

៣. **បង្កើនលទ្ធភាពដល់កសិករ ក្នុងការទទួលបានពូជស្រូវមានគុណភាពខ្ពស់ និងការស្រោចស្រព៖** ពូជស្រូវផ្សេងៗដែលអាជ្ញាធរមូលដ្ឋានកំពុងចែកចាយសព្វថ្ងៃ ដូចជា សែនពិដោរ និងផ្កាម្លិះ គឺសមស្របជាងសម្រាប់ការហូបចុកក្នុងគ្រួសារ។ រដ្ឋាភិបាលគួរសម្របសម្រួលការងារជាមួយ អ្នកនាំចេញអង្ករ ដើម្បីផ្តល់អាទិភាពដល់ពូជស្រូវដែលត្រូវជម្រុញឡើង និងចែកចាយពូជស្រូវមានគុណភាពខ្ពស់ក្នុងគោលដៅផលិតស្រូវអង្ករ ដែលស្របតាមតម្រូវការទីផ្សារនាំចេញ។ គោលនយោបាយសម្រាប់កែលំអហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព និងដែនគ្រប់ដណ្តប់ មានចុះនៅក្នុងគោលនយោបាយស្រូវ។ ដូច្នេះ រដ្ឋាភិបាល អាចជួយឲ្យកសិករកាន់តែមានលទ្ធភាពទទួលបានពូជស្រូវល្អ និងការស្រោចស្រព តាមការពន្លឿនការអនុវត្តគោលនយោបាយស្រូវបច្ចុប្បន្ន (RGC 2010)។

៤. **បន្ធូរការរឹតត្បិតឥណទានដល់កសិករ និងសហគ្រាសកសិពាណិជ្ជកម្ម៖** ការកែលំអលទ្ធភាពរបស់កសិករក្នុងការទទួលបានឥណទាន អាចជួយកាត់បន្ថយបញ្ហាលក់ស្រូវក្រៅកិច្ចសន្យា។ ការលើកកម្ពស់លទ្ធភាពសហគ្រាសកសិពាណិជ្ជកម្មក្នុងការទទួលបានឥណទានកសិកម្ម និង/ឬ ការបង្កើនឧបត្ថម្ភធន អាចជួយឲ្យមានវិនិយោគកាន់តែច្រើនទៅលើរោងចក្រកិនស្រូវ និងម៉ាស៊ីនសម្ងួត ហើយបន្ធូរបន្ថយតម្រូវការ

សាច់ប្រាក់ សម្រាប់ធ្វើការទូទាត់ជាទៀងទាត់ឲ្យកសិករ ហើយ វិធីនេះ ក៏ជួយកែលំអលំហូរសាច់ប្រាក់របស់កសិករផងដែរ។ ចំណុចនេះអាចសម្រេចបាន តាមការពន្លឿន ការអនុវត្តគោលនយោបាយស្រូវបច្ចុប្បន្ននេះដែរ (RGC 2010)។

៥. **បង្កើតអង្គភាពថ្នាក់ក្រោមជាតិមួយ សម្រាប់ការពង្រឹងអនុវត្ត និងធ្វើច្បាប់គ្រប់គ្រងកិច្ចសន្យា៖** វិធីនេះអាចជួយឲ្យកសិករ និងសហគ្រាសកសិពាណិជ្ជកម្ម មានអំណាច តថ្លៃស្មើគ្នា និងជួយកាត់បន្ថយករណីបំពានលើកិច្ចសន្យាពីសំណាក់ភាគីណាមួយ។ ដើម្បីអាចដំណើរការដោយមានប្រសិទ្ធភាពល្អ អង្គភាពនេះគួរអនុញ្ញាតឲ្យកសិករមកទាក់ទងខ្លួនបាន និងគួរមានសមាសភាពមកពីទាំងបួនក្រុម គឺកសិករ អាជ្ញាធរមូលដ្ឋាន សហគ្រាសកសិពាណិជ្ជកម្ម និង MAFF (ដែលជាក្រសួងជាប់ពាក់ព័ន្ធ)។

## ឯកសារយោង


Cai, J., L.Ung, S.Setboonsarng and P. Leung (2008), "Rice Contract Farming in Cambodia: Empowering Farmers to Move beyond the Contract toward Independence", ADBI Discussion Paper 109 (Tokyo: Asian Development Bank Institute)

Mund, Jan-Peter (2011), "The Agriculture Sector in Cambodia: Trends, Processes and Disparities", *Pacific News,* No. 35, pp. 10-14

RGC, Royal Government of Cambodia (2010), *Policy Paper on the Promotion of Paddy Production and Rice Export* (Phnom Penh: Council of Ministers)

FAO/WFP, Food and Agriculture Organisation and World Food Programme (2012), *FAO/WFP Crop and Food Security Update Mission to Cambodia* (Rome: FAO and WFP)


# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស[១]

ផ្នែកនេះរៀបរាប់ពី សូចនាករសេដ្ឋកិច្ចសំខាន់ៗនៅក្នុងពិភពលោក នៅអាស៊ីខាងត្បូង និងអាស៊ីខាងកើត។

សេដ្ឋកិច្ចពិភពលោកហាក់កំពុងរើបឡើងវិញ ប៉ុន្តែភាពមិនប្រាកដប្រជា និងភាពងាយរងគ្រោះនៅតែកើតមានជាបន្ត ដោយសារសេដ្ឋកិច្ចប្រទេសឧស្សាហកម្មធំៗ នៅមានកំណើនយឺត និងបន្តឡើងចុះ។ តំបន់អាស៊ីអាគ្នេយ៍ និងអាស៊ីខាងកើត នៅតែជាកម្លាំងជំរុញចម្បងនៃការរើបសេដ្ឋកិច្ចពិភពលោក ថ្វីបើប្រទេសខ្លះមានកំណើនយឺតជាងមុនក្តី។

នៅត្រីមាសទី១ កំណើន ផសស ពិតនៅឥណ្ឌូនេស៊ីធ្លាក់ចុះបន្តិចមកត្រឹម ៥,៨% ធៀបនឹង ៦,០% កាលពីត្រីមាសមុន និង ៦,៤% កាលពីមួយឆ្នាំមុន។ កំណើន ផសស របស់ម៉ាឡេស៊ី កើនដល់ ៤,៣% ធៀបនឹង ៤,១% កាលពីត្រីមាសមុន ប៉ុន្តែធ្លាក់ចុះបើធៀបនឹងអត្រា ៥,៤% កាលពីមួយឆ្នាំមុន។ កំណើន ផសស នៅសិង្ហបុរី កើនខ្ពស់បំផុតគិតចាប់ពីឆ្នាំ២០១១ មក ដល់ ៣,៧% ធៀបនឹង ១,៩% កាលពីមួយឆ្នាំមុន។ សេដ្ឋកិច្ចប្រទេសចិន រីកលូតលាស់យឺតជាងមុនបន្តិច ប៉ុន្តែនៅតែមានកំណើនដ៏លឿនបំផុតមួយ ដោយមានអត្រាជាមធ្យម ៧,៦% សម្រាប់រយៈពេល ៥ត្រីមាសចុងក្រោយ។ ផសស ពិតរបស់ចិន នៅត្រីមាសទី២ ធ្លាក់ចុះបន្តិចមកត្រឹម ៧,៥% ធៀបនឹង ៧,៧% កាលពីត្រីមាសមុន និង ៧,៦% កាលពីឆ្នាំមុន។ មានការវាយស្មានថា សេដ្ឋកិច្ចចិនអាចកើនយឺតជាងមុន ប្រសិនបើចិនមិនធ្វើការកែតម្រូវរចនាសម្ព័ន្ធដ៏ចាំបាច់ៗនោះទេ។ បញ្ហាជាច្រើន ដូចជា អំពើពុករលួយរបស់មន្ត្រីជាន់ខ្ពស់, អប្រសិទ្ធភាពនៃសហគ្រាសរដ្ឋ និងបរិយាកាសអាជីវកម្មមានការរើសអើង ចំពោះវិនិយោគិនបរទេស គឺត្រូវតែដោះស្រាយ។ ប្រទេសចិនក៏ត្រូវស្វែងរកដំណោះស្រាយដោយសន្តិវិធីលើ បញ្ហាជម្លោះដណ្តើមដែនកោះមួយចំនួន ដើម្បីកុំឲ្យវាឈានដល់ការប្រើសកម្មភាពយោធា ហើយខូចខាតដល់សេដ្ឋកិច្ច និងនយោបាយ។ កំណើន ផសស ពិតនៅហុងកុង កើនដល់ ៣,៣% ធៀបនឹង ២,៨% កាលពីត្រីមាសមុន ហើយកំណើន ផសស ពិតនៅកូរ៉េខាងត្បូង កើនដល់ ២,៣% ធៀបនឹង ១,៥% កាលពីត្រីមាសមុន។

នៅត្រីមាសទី២ ការរើបសេដ្ឋកិច្ចឡើងវិញនៅតំបន់អឺរ៉ូ នៅតែបន្តឡើងចុះ។ កំណើន ផសស បានរួមចុះមកដល់ ០,៧% ធៀបនឹង ១,១% កាលពីត្រីមាសទី១។ ភាពគ្មានការងារធ្វើ ជាពិសេសក្នុងចំណោមយុវជន នៅមានកម្រិតខ្ពស់នៅតាមបណ្តាប្រទេស ដូចជា អេស្ប៉ាញ និង អ៊ីតាលី ជាដើម។ ការសម្រេចបានសមត្ថភាពប្រកួតប្រជែងក្នុងចំណោមប្រទេសជាសមាជិក ក៏ជាបញ្ហាប្រឈមមួយដែរ។ សេដ្ឋកិច្ចជប៉ុន មានកំណើនយឺតត្រឹម ០,៤% ធៀបនឹង ២,៨% កាលពីមួយឆ្នាំមុន។ សហរដ្ឋអាមេរិកបន្តមានដំណើរការសេដ្ឋកិច្ចល្អ បើធៀបនឹងប្រទេសមានសេដ្ឋកិច្ចជឿនលឿនដទៃទៀត ទោះបីកំណើនធ្លាក់ចុះបន្តិចនៅត្រីមាសទី២ មកត្រឹម ១,៤% ធៀបនឹង ១,៨% កាលពីត្រីមាសមុនក្តី។

[១] អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។